គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC – BCV-CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CJR- CSD - CWCC - GENEROUS - HROTP
IDA_KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីថ្លែងការណ៍

## គណៈកម្មាធិការប្រព្រឹត្តិកម្ម សំដែងការបារម្ភចំពោះនីតិវិធីសវនាការបណ្តឹងឧទ្ធរណ៍

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធ នៃ សមាគមអង្គការមិនមែនរដ្ឋាភិបាលមានសមាជិកចំនួន ២៣ សូមសំដែងនូវការព្រួយបារម្ភ ចំពោះដំណើរការនីតិវិធីរបស់សាលាឧទ្ធរណ៍ ដែលបានប្រព្រឹត្តទៅឡើងចំពោះករណីបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ចំនួនបីរូប គឺ លោក សម រង្ស៊ី (អ្នកតំណាងរាស្ត្រ នៃគណបក្សសមរង្ស៊ី), លោកស្រី មាស ស្រី និងលោក ព្រំ ជា កាលពីវេលាព្រឹកថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១០។

យោងទៅតាមអង្គហេតុ និងប្រភពព័ត៌មានដែលគណៈកម្មាធិការប្រព្រឹត្តិកម្ម បានទទួលជុំវិញការអនុវត្តន៍ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ទៅលើករណីនេះ បង្ហាញថា មេធាវីការពារក្តីជនជាប់ចោទ បានស្នើសុំឱ្យមានការលើកពេលវេលាសំរាប់ការជំនុំជម្រះ ទៅលើករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងជនជាប់ចោទបីរូបខាងលើ ដែលត្រូវបានសាលាដំបូងខេត្តស្វាយរៀងកាត់ក្តីពី “បទធ្វើឱ្យខូចខាតដោយចេតនាតម្រុយបង្គោលព្រំដែនលេខ ១៨៥ កម្ពុជា-វៀតណាម” និង “ការញុះញង់ឱ្យមានការរើសអើងជាតិសាសន៍” ដោយចេញសាលក្រមលេខ ០១(ក) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០។ នៅក្នុងសវនាការចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ ក្រុមមេធាវីការពារក្តីឱ្យជនជាប់ចោទបានស្នើសុំដល់ក្រុមប្រឹក្សាឱ្យលើកពេលវេលាសំរាប់ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ដោយលើកមូលហេតុអវត្តមានកូនក្តីពីររូប ដែលកំពុងត្រូវបានដាក់ឃុំខ្លួន នៅពន្ធនាគារខេត្តស្វាយរៀង និង មួយរូបទៀត គឺ លោកតំណាងរាស្ត្រ សម រង្ស៊ី ដែលកំពុងនិរទេសខ្លួននៅឯបរទេស។ ក្រុមមេធាវីការពារក្តីបានជូនអំណះអំណាងផ្លូវច្បាប់ដល់អង្គចៅក្រមសាលាឧទ្ធរណ៍ដើម្បីសុំលើកពេលជំនុំជម្រះ ដោយសារតែនៅខណៈនោះ អវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ។ ប៉ុន្តែភ្លាម១បន្ទាប់ពីនោះ ក្រុមប្រឹក្សាមិនបានសំរេចតាមសំណើរបស់មេធាវីការពារក្តីទេ តែបន្ទាប់ពីការដើរចេញរបស់ក្រុមមេធាវីការពារក្តីមួយរយៈ ទើបក្រុមប្រឹក្សាបានសំរេចលើកពេលជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដោយមិនទាន់កំណត់ពេលវេលាច្បាស់លាស់នៅឡើយ ដែលនេះគឺជារឿងមិនប្រក្រតីមួយ។

ដូចនេះ ដើម្បីចៀសវាងការអនុវត្តន៍មិនប្រក្រតី មិនស្របតាមនីតិវិធីច្បាប់នៅពេលខាងមុខទៀត គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមស្នើសុំឱ្យចាត់វិធានការដូចខាងក្រោមៈ

១- តុលាការ ត្រូវធានាថា សិទ្ធិជនជាប់ចោទត្រូវបានគោរពនៅគ្រប់តំណាក់កាល នៃការជំនុំជម្រះ គឺថា សវនាការព្រហ្មទណ្ឌ ត្រូវធ្វើនៅចំពោះមុខវត្តមានរបស់ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទ

ស្របទៅតាមនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា ព្រមទាំង កតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលប្រទេសកម្ពុជាជាហត្ថលេខី និងចែងទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។

២- អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ គួរគប្បីធ្វើការតាមដាន និងដាក់បញ្ជោរដល់អាជ្ញាធរពន្ធនាគារ ឱ្យធ្វើការបញ្ជូនជនជាប់ចោទពាក់ព័ន្ធ នៅមុនពេលបើកសវនាការបណ្តឹងឧទ្ធរណ៍ ដើម្បីចៀសវាងអវត្តមានជនជាប់ចោទនោះ និងខកពេល នៅក្នុងពេលជំនុំជម្រះបណ្តឹងឧទ្ធរណ៍។

៣- ថេរវេលាក្នុងការបើកសវនាការបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសារទុក្ខ របស់សាលាឧទ្ធរណ៍ ឬតុលាការកំពូល មិនគួរឱ្យយូរជាងទំហំទោសជាក់ស្តែងដែលសាលាដំបូងសំរេចផ្តន្ទាទោសទៅលើជនជាប់ចោទនោះទេ ។ ការធ្វើដូចនេះ គឺ ដើម្បីធានាឱ្យបាននូវការជំនុំជម្រះក្តីមួយឱ្យក្នុងពេលវេលាសមរម្យ និងមិនពន្យាពេល ដែលជាសិទ្ធិមួយរបស់ជនជាប់ចោទគ្រប់រូប។

៤- សាលាឧទ្ធរណ៍ គួរតែធ្វើការស៊ើបសួរបន្ថែមពីលើសាលាដំបូងខេត្ត-ក្រុង ដោយមិនត្រូវរង់ចាំកាត់ក្តីតែតាមឯកសារសំណុំរឿង ដែលបានបញ្ជូនមកនោះទេ ក្នុងគោលបំណងស្វែងរកដើម្បីផលប្រយោជន៍យុត្តិធម៌ជូនភាគី។

*ភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១០*

☏ **<u>សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:</u>**


| | | |
|---|---|---|
| លោក ហង្ស ឆាយា | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក សុក សំអឿន | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោក ចាន់ សុវ៉ែត | ប្រធានផ្នែកសិទ្ធិមនុស្ស នៃសមាគមអាដហុក | ទូរស័ព្ទលេខ: ០១៦ ៩៣៧ ៥៩១ |
| លោកស្រី ស៊ុន ចាន់សែន | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី សយ សារាវឌ្ឍនី | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |